# នី តិ រដ្ឋ

(ឬធម្មាធិបតេយ្យ)

## ក) មុខងារជាចំបងនៃច្បាប់

ដើម្បីព្រាងច្បាប់ ឬយ៉ាងហោចណាស់ដើម្បីផ្តល់យោបល់លើពង្រាងច្បាប់ ទាមទារការយល់ដឹងស៊ីជម្រៅអំពីតួនាទី និងមុខងាររបស់ច្បាប់ ។ មានតែការយល់ដឹងដ៏ស៊ីជម្រៅដូចពោលមកទេ ទើបគេអាចកំណត់អំពីតម្រូវការ និងល័ក្ខខ័ណ្ឌអប្បបរមា សំរាប់តាក់តែងច្បាប់បាន ។ ដូច្នេះ គ្រាន់តែពោលពាក្យថា "នីតិរដ្ឋ" ដូចមនុស្សគ្រប់គ្នាធ្លាប់តែពោលនោះ មិនទាន់គ្រប់គ្រាន់ទេ ហើយទាមទារការវិភាគយ៉ាងហ្មត់ចត់លើពាក្យនេះ និងតួនាទីរបស់ច្បាប់ ។

ទាក់ទងនឹងសិទ្ធិ[១៩] របស់សមាជិកសង្គម ច្បាប់ចែងអំពីៈ

- ការដោះស្រាយទំនាស់ប្រកបដោយតុល្យភាព គ្មានអំពើហិង្សា រវាងសិទ្ធិមនុស្ស
- ការកំណត់លើគោលបំណង និងកម្រិតនៃការដាក់កំហិតលើសិទ្ធិមនុស្ស ។
- ក្របខ័ណ្ឌវិធាន និងដំណោះស្រាយបញ្ហាសំរាប់សមាជិកសង្គម និងល័ក្ខខ័ណ្ឌដែលអាចព្យាករបាននៃជីវិត ដែលធានាសន្តិភាព សុវត្ថិភាព ស្ថេរភាព និងការរីកចំរើនផ្នែកសេដ្ឋកិច្ច ។

ទាក់ទងនឹងគោលការណ៍នៃ**ការបែងចែងអំណាច** ច្បាប់ៈ

- សម្តែងនូវឆន្ទៈរបស់ប្រជារាស្ត្រ
- កំណត់អំណាចនីតិប្រតិបត្តិ និងផ្តល់ការណែនាំដល់អង្គនីតិបញ្ញត្តិ ព្រមទាំង
- មានតួនាទីជាខ្នាតរង្វាស់សំរាប់ការដោះស្រាយទំនាស់ដោយតុលាការ ។

## ខ) ច្បាប់ និងការការពារសិទ្ធិមនុស្ស

### I) តុល្យភាពរវាងសិទ្ធិមនុស្សដែលមានទំនាស់ៈ

មុខងារចំបងរបស់ច្បាប់គឺ **ដើម្បីការពារសិទ្ធិរបស់សមាជិកសង្គម** ។ ចំណុចនេះមានចែងយ៉ាងច្បាស់នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)ៈ

> បុព្វកថា III UDHR:
>
> ដោយហេតុថា កិច្ចគាំពារទាំងឡាយរបស់មនុស្សដោយរបបធម្មាធិប្បតេយ្យមួយ ជាការមានសារៈសំខាន់ ដើម្បីកុំឱ្យមនុស្សបង្ខំចិត្តយកការប៉ះបោរជាការសំអាងឧត្តមបំផុត ដើម្បីប្រឆាំងតទល់ នឹងអំណាចផ្តាច់ការ និងអំពើសង្កត់សង្កិន ។

[១៩] មើលសៀវភៅរបស់វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ភាគទី១ ស្តីពី "ការវិភាគផ្នែកគតិយុត្តិ — សិទ្ធិមនុស្ស" ទំព័រទី ២ ដល់ ២៤

ដោយមនុស្សជាតិមានសិទ្ធិស្មើគ្នា ច្បាប់ត្រូវ**ដោះស្រាយទំនាស់រវាងសិទ្ធិមនុស្ស** របស់សមាជិកសង្គមម្នាក់ៗ នៅក្នុងសង្គម ។ ច្បាប់ត្រូវពិចារណាលើសិទ្ធិរបស់ភាគីទាំងសងខាង ដែលពាក់ព័ន្ធនៅក្នុងទំនាស់នោះ ហើយត្រូវ**ថ្លឹងថ្លែងនូវសិទ្ធិទាំងនេះ** ។

***ភារកិច្ចរបស់អ្នកធ្វើច្បាប់ គឺត្រូវពិនិត្យមើល និងស្វែងរកតុល្យភាពមួយ!***

## II) លក្ខខណ្ឌសំរាប់ការដាក់កំហិតលើសិទ្ធិមនុស្ស:

ដើម្បីការពារសេរីភាព និងសិទ្ធិមនុស្សរបស់បុគ្គលម្នាក់ (ក) ច្បាប់ត្រូវដាក់កំហិតលើសេរីភាពរបស់បុគ្គល (ខ) ម្នាក់ទៀត ។ ប៉ុន្តែ ដោយសារបុគ្គល (ខ) ក៏មានសិទ្ធិដែរនោះ ការដាក់កំហិតលើសិទ្ធិរបស់បុគ្គលនោះត្រូវតែមានសមាមាត្រគ្នា (មិនត្រូវតឹងតែងហួសពីការចាំបាច់នោះទេ) ។ ដូច្នេះនៅទីបំផុត សិទ្ធិត្រូវតែមានតុល្យភាព ។




ឧទាហរណ៍:

ដើម្បីការពារសិទ្ធិរស់នៅ និងដើម្បីទទួលបានបូរណភាពរូបកាយរបស់មនុស្ស ដែលរួមធ្វើចរាចរតាមដងផ្លូវ ច្បាប់ត្រូវកំណត់សេរីភាពរបស់អ្នកបើកបររថយន្ត ក្នុងការធ្វើដំណើរទៅមកតាមចំណង់របស់ខ្លួនដោយកំណត់កំរិតល្បឿនសំរាប់អ្នកបើកបរទាំងនោះ។ ប៉ុន្តែកំរិតល្បឿននេះ មិនត្រូវតឹងតែងរហូតទាល់តែអ្នកបើកបរបាត់បង់សេរីភាពក្នុងការធ្វើដំណើរទាំងស្រុងឡើយ ។ ការកំរិតតឹងតែងបែបនេះ មិនមានសមាមាត្រទៀតទេ ។ ឧទាហរណ៍: កំរិតល្បឿនតែ២គីឡូម៉ែតក្នុង១ម៉ោងសំរាប់រថយន្តធុនតូច និងម៉ូតូ ដូចជាតឹងរឹងពេក ព្រោះជាការចាំបាច់គួរតែកំណត់ត្រឹម៣០ ឬ៤០ គីឡូម៉ែតក្នុង១ម៉ោង ។

ដើម្បីធានាឱ្យមានការគោរពសិទ្ធិ និងផលប្រយោជន៍របស់ភាគីទាំងសងខាង ហើយការដាក់កំហិតលើសិទ្ធិទាំងនេះ ត្រូវធ្វើឡើងតែក្នុងករណីចាំបាច់នោះ ទស្សនៈសិទ្ធិមនុស្សកំណត់ **លក្ខខណ្ឌបីសំរាប់ការដាក់កំហិតលើសិទ្ធិមនុស្ស:**

**ដូច្នេះនៅពេលដែលសមាជិកសភាពព្រាងច្បាប់ថ្មីមួយ ពួកគេត្រូវតែគោរពគោល-ការណ៍ទាំងបីនេះ!**

- **ទំរង់:** គេអាចដាក់កំហិតលើសិទ្ធិមនុស្សបាន តែក្នុងទំរង់**ច្បាប់**ប៉ុណ្ណោះ ព្រោះមានតែច្បាប់ប៉ុណ្ណោះ ដែលអាចធានាថាសិទ្ធិនៃភាគីទាំងសងខាងត្រូវបានគេយកមកពិចារណាដោយដំណើរការធ្វើការសំរេចចិត្តរួមមួយ ។ អនុក្រិត្យ ឬប្រកាសធម្មតាមួយដែលចេញដោយរដ្ឋាភិបាល មិនគ្រប់គ្រាន់សំរាប់ការតំរូវជាផ្លូវការដ៏តឹងរឹងនេះទេ ។
- **គោលបំណង:** ច្បាប់នេះអាចបំរើតែគោលបំណង**ការពារសិទ្ធិសេរីភាពរបស់មនុស្ស**ប៉ុណ្ណោះ ដូចដែលមានរៀបរាប់យ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ ។
- **ប្រពលភាព:** ការដាក់កំហិតដោយច្បាប់ទៅលើសិទ្ធិមនុស្ស ត្រូវតែ**សមាមាត្រ** ។ វិធានការនេះមិនត្រូវតឹងតែងហួសពី**ការចាំបាច់**ឡើយ ។

លក្ខខ័ណ្ឌទាំងបីនេះ មានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) :

> មាត្រា២៩ II UDHR:
>
> ក្នុងការប្រតិបត្តិសិទ្ធិសេរីភាពទាំងឡាយ និងក្នុងការគ្រេបរសជាតិនៃសេរីភាពរបស់គេមនុស្សម្នាក់ៗ គ្រាន់តែស្ថិតក្នុងព្រំដែនដែលច្បាប់បានកំណត់ប្រយោជន៍ឱ្យមានការទទួលខុសស្គាល់ និងគោរពដល់សិទ្ធិ និងសេរីភាពទាំងឡាយរបស់អ្នកដទៃ និងដើម្បីឆ្លើយតបនឹងការតម្រូវទាមទារដ៏ពិសិដ្ឋនៃសីលធម៌ នៃរបៀបរៀបរយសាធារណៈ និងនៃសុខមាលភាពទូទៅនៅក្នុងសង្គមប្រជាធិបតេយ្យ ។

> ឧទាហរណ៍: **មាត្រា១៩ II ២ ក) ខ) ICCPR:**
>
> ការអនុវត្តសិទ្ធិដូចមានចែងនៅក្នុងកថាខ័ណ្ឌទី២ នៃមាត្រានេះ ត្រូវប្រទះនឹងករណីយកិច្ច និងការទទួលខុសត្រូវពិសេស ។ ដូច្នេះ វាត្រូវស្ថិតនៅក្រោមការដាក់កម្រិតលក្ខខ័ណ្ឌ និងបទបញ្ជាផ្សេងៗ កំណត់ដោយច្បាប់ជាចាំបាច់:
>
> ក) ដើម្បីគោរពសិទ្ធិ និងកិត្តិនាមអ្នកដទៃ
>
> ខ) ដើម្បីការពារសន្តិសុខជាតិ របៀបរៀបរយសាធារណៈ ព្រមទាំងសុខុមាលភាព និងសីលធម៌សាធារណៈ ។

ឧទាហរណ៍:

វាជាការរំលោភសិទ្ធិមនុស្សក្នុងការទទួលបាន សេរីភាពនៃការប្រកបអាជីវកម្ម នៅពេលដែលហាងខារ៉ាអូខេទាំងអស់ត្រូវបានបិទទ្វារ តាមការបញ្ជាដ៏សាមញ្ញរបស់នាយករដ្ឋមន្ត្រីដែលគ្មានមូលដ្ឋានច្បាប់ ។ ការដាក់កំហិតដ៏ធ្ងន់ធ្ងរទៅលើសិទ្ធិប្រកបមុខរបរដោយសេរីបែបនេះ អាចធ្វើទៅបានតែតាមរយៈ**ច្បាប់**ប៉ុណ្ណោះ ទោះបីជាករណីបិទហាងទាំងនេះ ជាការចាំបាច់ក៏ដោយ ។

### III) ស្ថេរភាពតាមរយៈការដោះស្រាយទំនាស់ដោយអហិង្សាតាមផ្លូវច្បាប់:

ដោយការផ្តល់នូវដំណោះស្រាយទំនាស់ទូទៅមួយ ច្បាប់បង្កើតនូវក្របខ័ណ្ឌវិធានសំរាប់សមាជិកនៃសង្គមមួយ ។ ការទទួលយក និងអនុវត្តនីវិធានដូចពោលខាងលើនេះ បង្កើតបានជាបរិយាកាសមួយប្រកបដោយសន្តិសុខ និងស្ថេរភាព ដែលមិនត្រឹមតែជំរុញឱ្យមានសន្តិភាពនៅក្នុងសង្គមប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងលើកទឹកចិត្តឱ្យមានវិនិយោគ ព្រមទាំងគាំទ្រដល់កំណើនសេដ្ឋកិច្ចទៀតផង (ចូរមើលបុព្វកថានៃ UDHR ICCPR និងរដ្ឋធម្មនុញ្ញកម្ពុជា) ។ បើគ្មានដំណោះស្រាយទំនាស់ប្រកបដោយតុល្យភាពទេនោះ ភាពតានតឹងនៅក្នុងសង្គមកើនឡើង ហើយមនុស្សដែលមើលឃើញថា សិទ្ធិជាមូលដ្ឋានរបស់ខ្លួនមិនត្រូវបានគេគោរពនោះ បែរមកប្រើអំពើហិង្សា ដើម្បីបង្ហាញពីតំរូវការដែលមិនបានទទួលការគោរព ឬក៏ដោះស្រាយទំនាស់របស់ខ្លួនដោយដំណោះស្រាយហិង្សា ឬព្យាយាមដោះខ្លួនពីការគាបសង្កត់ដោយប្រើអំណាច និងអំពើហិង្សា ប្រឆាំងនឹងអ្នកទន់ខ្សោយ ។

ឧទាហរណ៍:

ប្រជាជននាំគ្នាសំលាប់ចោរតាមក្នុងចំណោមហ្វូងមហាជន ។

បុរសវាយ ប្រពន្ធ និងកូនជាដើម ។

## គ) ច្បាប់ និងការបែងចែកអំណាច

### I) ច្បាប់បង្ហាញពីឆន្ទៈប្រជាពលរដ្ឋ:

តាមគោលការណ៍លទ្ធិប្រជាធិតេយ្យ មុខងារជាមូលដ្ឋានរបស់ច្បាប់ គឺការបង្ហាញពីឆន្ទៈរបស់ប្រជាពលរដ្ឋតាមរយៈអ្នកតាក់តែងច្បាប់នៅក្នុងសភាជាតិ ។

មាត្រា ១៧ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៤៧:
ច្បាប់ គឺជាការសំដែងឆន្ទៈជាតិ ។

ទំនាស់នៅក្នុងសង្គម ត្រូវដោះស្រាយតាមទំរង់ច្បាប់ តាមរយៈតំណាងដែលបានជាប់ឆ្នោតនៃសមាជិកសង្គម ក្រោយពីការពិភាក្សាជាសាធារណៈ ។

### II) គ្មានការជំនួសច្បាប់ ដោយប្រកាស និងអនុក្រឹត្យរបស់រដ្ឋាភិបាលឡើយ:

ការសំរេចចិត្តសំខាន់ៗ ត្រូវធ្វើឡើងដោយសមាជិកសភា តាមទំរង់ច្បាប់ និង **មិនមែនធ្វើឡើងដោយរដ្ឋាភិបាលតាមទំរង់ប្រកាស** ឬអនុក្រឹត្យនោះទេ ។

នេះជាអត្ថន័យដ៏សាមញ្ញនៃពាក្យថា "នីតិរដ្ឋ ឬ វិធាននៃច្បាប់" វាមិនមែនមានន័យថា "វិធាននៃប្រកាស" ឬ "វិធាននៃអនុក្រិត្យ" នោះទេ ។

ឧទាហរណ៍:

ការបោះឆ្នោតជ្រើសរើសព្រឹទ្ធសភា ការបង្កើតសមាជជាតិ ឬការឡើងគ្រងរាជសម្បត្តិជាដើម ត្រូវកំណត់ដោយច្បាប់ (មើលមាត្រា ១៣ III មាត្រា ១០១ និង ១៤៩ II CC) ។

ដូចគ្នាដែរចំពោះ:

- របបសារព័ត៌មាន (មាត្រា ៤១ II CC)
- ការបង្កើតសហជីព (មាត្រា ៣៦ VI CC)
- ការកំហិតសិទ្ធិបោះឆ្នោត (មាត្រា ៣៤ V CC)

"ត្រូវតែកំណត់ដោយច្បាប់" ។

ភាពខុសគ្នាខាងក្រោម បង្ហាញយ៉ាងច្បាស់អំពីអត្ថប្រយោជន៍សំខាន់ៗនៃដំណើរការតាក់តែងច្បាប់បែបប្រជាធិបតេយ្យ:

**ដំណើរការតាក់តែងច្បាប់...**

**...ច្បាប់**

**១) តម្លាភាព:**

- ការពិភាក្សានៅក្នុងសភា
- សវនាការរបស់គណៈកម្មការ
- ការផ្សព្វផ្សាយពេញលេញ

**២) ការពិនិត្យដោយតុលាការ**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់

**...ប្រកាស ឬអនុក្រឹត្យ**

**១) គ្មានតម្លាភាព**

- គ្មានការពិភាក្សានៅក្នុងសភា
- គ្មានសវនាការរបស់គណៈកម្មការ
- គ្មានការផ្សព្វផ្សាយពេញលេញ

**២) មិនមានអំណាចតុលាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យដោយផ្ទាល់លើ ធម្មនុញ្ញភាពនៃអនុក្រឹត្យ ឬប្រកាសនោះទេ**

រដ្ឋាភិបាលមានតែភារកិច្ចការពារ និងគោរពច្បាប់ប៉ុណ្ណោះ ប៉ុន្តែគ្មានករណីយកិច្ចក្នុងការធ្វើច្បាប់ឡើយ ។ តួនាទីរបស់រដ្ឋាភិបាលក្នុងដំណើរការធ្វើច្បាប់ គឺត្រូវកំណត់ឱ្យមានតែអំណាចផ្តួចផ្តើមគំនិតធ្វើច្បាប់ប៉ុណ្ណោះ ប៉ុន្តែមិនត្រូវមានអំណាចអនុម័តផ្នែកណាមួយនៃច្បាប់ទេ ។

មាត្រា៩២ ឃ្លាទី ២ CC:

រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

មាត្រា៩១ I CC:

សមាជិកព្រឹទ្ធសភា តំណាងរាស្ត្រ និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

## III) ការកំណត់អំណាចនីតិប្រតិបត្តិដោយច្បាប់:

ហេតុផលដ៏សាមញ្ញសំរាប់កំណត់តួនាទីរបស់រដ្ឋាភិបាលក្នុងដំណើរការតាក់តែងច្បាប់ គឺថា ច្បាប់ជាអ្នកផ្តល់ការណែនាំដល់អង្គនីតិប្រតិបត្តិ និងកំណត់ការប្រើប្រាស់អំណាចនីតិប្រតិបត្តិ ដើម្បីការពារសិទ្ធិពលរដ្ឋ ។ ដំណើរការនេះនឹងមិនត្រូវបានធានាទេ ប្រសិនបើផ្នែកនីតិប្រតិបត្តិជាអ្នកផ្តល់ការណែនាំដោយខ្លួនឯង ។ អំណាចស្វ័យគ្រប់គ្រងរបស់អង្គនីតិប្រតិបត្តិ អាចនាំឆ្ពោះទៅរកមជ្ឈការប្រមូលផ្តុំអំណាចយ៉ាងងាយ និងឆាប់រហ័ស ហើយបន្ទាប់មកអាចនាំឱ្យមានការរំលោភអំណាច ដែលប្រទេសកម្ពុជាបានជួបប្រទះជាច្រើនលើកមកហើយនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ។

### ១) គ្មានប្រតិភូកម្មអំណាចធ្វើច្បាប់ពីរដ្ឋសភា ទៅរដ្ឋាភិបាលទេ:

ចូរចងចាំថា តំណាងរាស្ត្រជាប់ឆ្នោត ក៏អាចនឹងបំពានគោលការណ៍បែងចែកអំណាចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញដែរ ( មាត្រា៩១ IV CC) ប្រសិនបើតំណាងរាស្ត្រ បានអនុម័តច្បាប់ដែលបណ្តោយឱ្យអង្គនីតិប្រតិបត្តិធ្វើការសំរេចចិត្តសំខាន់ៗ និងដោះស្រាយទំនាស់តាមទំរង់ប្រកាស ឬអនុក្រិត្យនោះ។ ក្នុងករណីនេះ អង្គនីតិបញ្ញត្តិមិនបានបំពេញករណីយកិច្ចរបស់ខ្លួន និងអាណត្តិដែលប្រជាពលរដ្ឋកម្ពុជាជាម្ចាស់ឆ្នោតប្រគល់ឱ្យឡើយ ។

ដូច្នេះ **ផ្នែកនីតិបញ្ញត្តិ<u>មិន</u>អាចអនុញ្ញាត្តិអំណាចអោយរដ្ឋាភិបាល និងក្រសួងនានា ដើម្បីបំពេញតួនាទីប្រហាក់ប្រហែល អង្គនីតិបញ្ញត្តិ ដូចជាអ្នកម៉ៅការបន្តនោះបានទេ** ។ ផ្ទុយទៅវិញ ការសំរេចចិត្តសំខាន់ៗត្រូវតែធ្វើឡើងដោយច្បាប់ ។ មានតែកិច្ចការលំអិតនៃរដ្ឋបាលតូចតាចប៉ុណ្ណោះ ទើបអាចប្រគល់ទៅឱ្យប្រកាស ឬអនុក្រិត្យរបស់រដ្ឋាភិបាលជាអ្នកចាត់ចែង ។ បើមិនដូច្នេះទេ អំណាចបង្កើតច្បាប់ នឹងត្រូវបង្វែរទៅឱ្យផ្នែកនីតិ-ប្រតិបត្តិ ដោយគ្មានអ្វីជាមូលដ្ឋាននៅក្នុងរដ្ឋធម្មនុញ្ញជាពុំខាន ។

មាត្រាច្បាប់ទាំងឡាយណា ដែលប្រគល់អំណាចសំរេចចិត្តសំខាន់ៗទៅឱ្យផ្នែកនីតិប្រតិបត្តិ សុទ្ធតែ<u>អធម្មនុញ្ញភាព</u>!

<u>ឧទាហរណ៍:</u>

- ក្នុងករណីជាច្រើននៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សាឃុំ-សង្កាត់ បានប្រគល់អំណាចទៅឱ្យ ប្រកាស និងអនុក្រិត្យរបស់ក្រសួងមហាផ្ទៃ ជាអ្នកឆ្លើយតបនឹងសំណួរសំខាន់ៗ នៃស្វ័យគ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

មាត្រា៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ផ្តល់ឱ្យរដ្ឋបាលឃុំ-សង្កាត់ នូវករណីយកិច្ចដែលមានលក្ខណៈមិនច្បាស់លាស់ និងទូលំទូលាយ ហើយមាត្រា៤៧ នៃច្បាប់ដដែលនេះចែងថា "តួនាទី មុខងារ និងអំណាច ដែលមានចែងនៅក្នុងមាត្រា៤៣ ត្រូវលំអិតដោយ<u>អនុក្រឹត្យមួយតាមសំណើររបស់ក្រសួងមហាផ្ទៃ</u>" ។

- មាត្រា៩ នៃពង្រាងច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ជាទូទៅចែងថា ការលើកលែងពីបំរាមជាទូទៅនៃ"ការកាន់កាប់អាវុធ អាចអនុញ្ញាតចំពោះជនស៊ីវិលបាន" រួចហើយក៏កំណត់ថា "លក្ខខណ្ឌ និងនីតិវិធីអនុវត្ត បទបញ្ញត្តិនេះ ត្រូវកំណត់ដោយ<u>អនុក្រឹត្យ តាមសំណើររបស់ក្រសួងមហាផ្ទៃ</u>" ។ ដូច្នេះ ពង្រាងច្បាប់នេះ បានប្រគល់អំណាចទាំងស្រុងទៅផ្នែកនីតិប្រតិបត្តិ ជាអ្នកសំរេចអំពីបញ្ហាដ៏សំខាន់ ថាតើនរណាខ្លះ និងក្រោមល័ក្ខខ័ណ្ឌអ្វីខ្លះដែលត្រូវបានលើកលែងពីបំរាមកាន់កាប់អាវុធនេះ! ក្នុងករណីនេះ ពង្រាងច្បាប់នេះថែមទាំងមិនបានផ្តល់គន្លឹះ ឬ ការណែនាំអ្វីមួយសំរាប់ឱ្យក្រសួងកំណត់ ថាតើលក្ខខណ្ឌអ្វីខ្លះ ដែលត្រូវកំណត់ និងមិនត្រូវកំណត់នៅក្នុងអនុក្រិត្យរបស់ខ្លួន ។

**ដូច្នេះ ជានិច្ចកាល អ្នកធ្វើច្បាប់ត្រូវតែប្រាកដថា ខ្លួនមិនត្រូវអនុម័តមាត្រាច្បាប់ថ្មី ដែលបង្វែរអំណាចធ្វើច្បាប់របស់ខ្លួនទៅឱ្យរដ្ឋាភិបាលឡើយ!**

**២) ការរំលោភលើការបែងចែកអំណាច ដោយភាពអសកម្មរបស់អង្គនីតិបញ្ញត្តិ:**

អង្គនីតិបញ្ញត្តិ ក៏រំលោភករណីកិច្ចរបស់ខ្លួនផងដែរ ប្រសិនបើបណ្តោយឱ្យទំនាស់ផ្សេងៗកើតមានឡើង ដោយគ្មានបទបញ្ញត្តិដែលទំនាស់ទាំងនោះ គួរតែមានការបញ្ញត្តិដោយច្បាប់ ។ ក្នុងករណីនេះ **កង្វះបទញ្ញត្តិច្បាប់បង្កឱ្យមានការបំពេញគម្លាត ឬភាពខ្វះចន្លោះនេះ** ដោយការធ្វើធម្មានុរូបមិនពេញលក្ខណៈតាមបែបលទ្ធិប្រជា-ធិបតេយ្យ **ដោយក្រឹត្យរបស់រដ្ឋាភិបាល ។**

គ្មានបទបញ្ញត្តិនៃច្បាប់ច្បាស់លាស់ទេនោះ **តុលាការក៏ត្រូវបង្ខំចិត្តបំពេញគម្លាតនេះ** តាមឆន្ទានុសិទ្ធិរបស់ខ្លួនដែរ ជាមួយសេចក្តីសំរេចបែបអត្តនោម័តច្រើន ឬតិច ឬតាមការសន្និដ្ឋានទៅលើដំណោះស្រាយ ទំនាស់មួយដែលអាចឃ្លាតចេញពីរដ្ឋធម្មនុញ្ញបាន ។

ឧទាហរណ៍:

- ដោយពុំទាន់មាន "ច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃសារការី" ត្រូវបានអនុម័តដោយសភាជាតិនោះ បុគ្គលម្នាក់ត្រូវបានតែងតាំងដោយអនុក្រឹត្យរបស់នាយករដ្ឋមន្ត្រី ដោយគ្មានដំណើរការ ជ្រើសរើសជាសាធារណៈ និងគ្មានតម្លាភាព ឬគ្មានទាំងការប្រកួតប្រជែង ដោយផ្តល់ដល់បុគ្គលម្នាក់នេះ នូវអំណាចយ៉ាងច្រើន និងគ្មានកំណត់លំអិត អំពីករណីកិច្ច និងសិទ្ធិរបស់មុខងារសាធារណៈនេះ ថាតើត្រូវធ្វើអ្វីខ្លះឡើយ ។
- ដោយមានច្បាប់សារពត៌មាន ក៏ប៉ុន្តែមិនមាន "ច្បាប់ស្តីពីការគ្រប់គ្រងបណ្តាញសារពត៌មាន" នៅឡើយនោះ ក្រសួងពត៌មានគ្រាន់តែចេញអាជ្ញាប័ណ្ណវិទ្យុ និងគ្រប់គ្រងកិច្ចការងារបណ្តាញសារពត៌មានអេឡិចត្រូនិចទាំងឡាយ តាមតែខ្លួនយល់ឃើញថាសមស្របតាមរយៈសេចក្តីណែនាំ ឬបទបញ្ជា ដោយផ្ទាល់ទៅបណ្តាញសារពត៌មានទាំងនោះ ។

ភាពអសកម្មរបស់ផ្នែកនីតិបញ្ញត្តិ គឺជាការរំលោភគោលការណ៍នៃការបែងចែងអំណាច !

**អ្នកធ្វើច្បាប់ ឬតំណាងរាស្ត្រ ត្រូវធានាថា ខ្លួនបានប្រើប្រាស់អាណត្តិរបស់ខ្លួន និងអនុម័តច្បាប់ទាំងឡាយដែលកំណត់ដោយរដ្ឋធម្មនុញ្ញ!**

## ឃ) <u>លក្ខខណ្ឌតំរូវជាមូលដ្ឋានចំពោះច្បាប់នានា</u>

ចេញមកពីមុខងារនានាដូចដែលបានពោលខាងលើ លក្ខខណ្ឌតំរូវជាមូលដ្ឋានមួយចំនួនចំពោះច្បាប់ ដែលជានិច្ចកាលអ្នកធ្វើច្បាប់ត្រូវចងចាំក្នុងចិត្ត :

ច្បាប់ត្រូវតែមានលក្ខណៈ :

- **យុត្តិធម៌** = ដោយយោងតាមសិទ្ធិមនុស្ស និងរដ្ឋធម្មនុញ្ញ
- **ទូទៅ** = មិនអនុវត្តចំពោះតែមនុស្សម្នាក់ ឬច្រើននាក់នោះទេ ប៉ុន្តែត្រូវអនុវត្តចំពោះគ្រប់ប្រជាពលរដ្ឋទាំងអស់ និងប្រព្រឹត្តិចំពោះជនគ្រប់រូបដោយស្មើភាព
- **អរូបី** = បំរើជាវិធានសំរាប់គ្រប់ករណីទាំងអស់ មិនមែនសំរាប់ដោះស្រាយតែករណីមួយនោះទេ
- **ច្បាស់លាស់** = រៀបចំពាក្យពេចន៍ ឱ្យបានច្បាស់លាស់ល្អម ដើម្បីបំពេញមុខងារជាការណែនាំសំរាប់ប្រជាពលរដ្ឋ អង្គនីតិប្រតិបត្តិ និងតុលាការ

## I) ច្បាប់ត្រូវតែមានលក្ខណៈ "យុត្តិធម៌":

អ្នកធ្វើច្បាប់ មិនមែនចេះចង់បង្កើតច្បាប់អ្វីក៏បានតាមចំណង់ទេ ប៉ុន្តែគេត្រូវគោរពតាមរដ្ឋធម្មនុញ្ញ ។ **គ្រប់ច្បាប់ទាំងអស់ ត្រូវស្របទៅតាមរដ្ឋធម្មនុញ្ញ និងត្រូវគោរពសិទ្ធិមនុស្ស** ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធទាំងអស់ ។

ហេតុផល គឺថាអ្នកធ្វើច្បាប់មិនមែនស្ថិតនៅពីលើសិទ្ធិមនុស្សទេ ប៉ុន្តែគេមានភារកិច្ចមិនមែនគ្រាន់តែគោរពសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវការពារ និងលើកកំពស់សិទ្ធិមនុស្សទាំងនោះទៀតផង ។ ដូច្នេះ អ្នកធ្វើច្បាប់ ទោះបីជាមានសំលេង២/៣ អាចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញក៏ដោយ ក៏គេមិនអាចលុបបំបាត់ការធានាដល់សិទ្ធិមនុស្សជាមូលដ្ឋានបានឡើយ ។

> មាត្រា ១៧ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៤៧:
>
> ច្បាប់ធានាដល់បុគ្គលគ្រប់រូបទាំងអស់ នូវការប្រើប្រាស់សិទ្ធិមនុស្ស ហើយគ្រប់កាលៈទេសៈទាំងអស់ មិនអាចគំរាមកំហែងសិទ្ធិទាំងនេះឡើយ ។

> មាត្រា១៥០ II CC :
>
> ច្បាប់ និងសេចក្តីសំរេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។
>
> មាត្រា ១៥៣ CC:
>
> ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ មិនអាចធ្វើទៅបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ ។

ដូច្នេះ ធម្មនុញ្ញភាពនៃច្បាប់នានា **គឺជាកម្មវត្ថុនៃការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ** ។ រដ្ឋធម្មនុញ្ញកម្ពុជាបញ្ញត្តិថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ច :

- ធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលអនុម័តដោយរដ្ឋសភា (មាត្រា ១៣៦ I CC)
- ពិនិត្យពង្រាងច្បាប់ មុននឹងត្រូវបានប្រកាសអោយប្រើ (មាត្រា ១៤០ I CC)
- ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ទាំងឡាយ ក្រោយពីប្រកាសអោយប្រើ (មាត្រា១៤១ I CC)
- ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីសិទ្ធិប្តឹងតវ៉ារបស់ប្រជាពលរដ្ឋ (មាត្រា១៤១ II CC)
- ប្រកាសមោឃភាពនៃច្បាប់អនុម័តដោយសភាជាតិ ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ (មាត្រា៩២ ប្រយោគទី២ CC)

ឧទាហរណ៍:

- ច្បាប់កម្ពុជាមួយ ដែលមានគោលបំណងតែមួយ ដើម្បីហាមប្រាមមិនឱ្យបង្កើតសហជីព (ដូចជាច្បាប់ខ្លះនៅសាធារណរដ្ឋប្រជាមានិតចិន) មិនស្របនឹងរដ្ឋធម្មនុញ្ញឡើយ ។ ច្បាប់នេះ មិនបំរើឱ្យគោលបំណងការពារសិទ្ធិបង្កើតសមាគម និងបង្កើតសហជីព (សូមមើលមាត្រា៣៦ V CC) តែមានគោលបំណងរំលាយសិទ្ធិនេះចោល ។
- ច្បាប់ដែលអនុញ្ញាតិឱ្យប៉ូលីសឆែកឆេរលំនៅដ្ឋាន ដោយគ្មានដីកាឆែកឆេរ ទោះបីជា ក្នុងករណីគ្មានការគំរាម-កំហែងជាបទល្មើសព្រហ្មទណ្ឌជាបន្ទាន់ក៏ដោយ ការឆែកឆេរនេះរំលោភរដ្ឋធម្មនុញ្ញដែរ ព្រោះច្បាប់នោះពុំមានសមាមាត្រ ប៉ុន្តែ ជាការកំណត់សេរីភាពឯកជន (មាត្រា៤០ IV CC និងមាត្រា១៧ I ICCPR) តឹងតែងហួសពីការចាំបាច់ ។

## II) ច្បាប់ត្រូវមានលក្ខណៈ "ទូទៅ":

**អត្ថបទច្បាប់ត្រូវអនុវត្តចំពោះគ្រប់ប្រជាពលរដ្ឋទាំងអស់** មិនមែនចំពោះតែបុគ្គលម្នាក់ ឬបុគ្គលមួយចំនួននោះទេ ។ ហេតុផលគឺថា សិទ្ធិមនុស្សជាមូលដ្ឋាន **គឺសមភាព** ។ ប្រសិនបើ ច្បាប់អនុវត្តចំពោះតែបុគ្គលមួយចំនួន ប៉ុន្តែមិនអនុវត្តចំពោះសមាជិកសង្គមទាំងមូល ច្បាប់នោះគ្មានយុត្តិធម៌ទេ ហើយនឹងផ្តល់បុព្វសិទ្ធិឱ្យទៅតែបុគ្គលមួយចំនួន (ឧទាហរណ៍:ការលើកលែង ឱ្យរួចពីនីតិរដ្ឋ ឬធម្មាធិបតេយ្យ) ។

> មាត្រា ៣១ II CC:
> ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ
>
> មាត្រា ៤៩ I CC:
> ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

តុលាការកំពូលរបស់ប្រទេសឥណ្ឌាធ្លាប់បាននិយាយថា: **"ទោះបីអ្នកមានឋានៈខ្ពង់ខ្ពស់យ៉ាងក៏ដោយ ក៏ត្រូវនៅក្រោមច្បាប់ដែរ"** នេះជាការបញ្ជាក់ពីគំនិតដែលថា ច្បាប់គឺជាលទ្ធផលនៃដំណើរការសំរេចចិត្តរួមគ្នាដែលត្រូវអនុវត្តចំពោះសមាជិកសង្គមទាំងអស់ ។ ដូច្នេះ យោងតាមរដ្ឋធម្មនុញ្ញ មិនថាតែព្រះមហាក្សត្រ សមាជិករដ្ឋាភិបាល ឬសមាជិករដ្ឋសភា ឬជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញឡើយ ត្រូវស្ថិតនៅក្រោមច្បាប់ ហើយត្រូវគោរពច្បាប់ ហើយច្បាប់ត្រូវអនុវត្តចំពោះអ្នកទាំងអស់នោះ ។

ឧទាហរណ៍:

ឧបសម្ព័ន្ធ VII បង្ហាញថា ព្រះមហាក្សត្រ និងរាជរដ្ឋាភិបាលត្រូវធ្វើសច្ចាប្រណិធាន តាមរដ្ឋធម្មនុញ្ញដោយត្រូវគោរពតាមអ្វីដែលបានសន្យា ។ មាត្រា១២៦ CC ក៏បង្ហាញផងដែរថា មាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងខ្លួនអំពីការដែលខ្លួនបានប្រព្រឹត្ត ។ ចំណែកឯមាត្រា១០ III នៃច្បាប់ស្តីពីការបង្កើត និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បង្ហាញថា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញរូបណា ដែលត្រូវបាន

កាត់ទោសដោយតុលាការព្រហ្មទណ្ឌ ពីបទល្មើសមជ្ឈឹម និងបទឧក្រិដ្ឋត្រូវដកចេញពីតំណែងដោយស្វ័យប្រវត្តិ ។ មាត្រា៨០ III CC ចែងថា សមាជិករដ្ឋសភា ក៏គ្មានសិទ្ធិរំលោភច្បាប់តាមចំណង់ដែរ ហើយអាចត្រូវបាត់បង់អភ័យឯកសិទ្ធិក្នុងករណីធ្ងន់ធ្ងរដោយមានការអនុម័តយល់ព្រមពីរដ្ឋសភា ។

ដូច្នេះ នៅពេលព្រាងច្បាប់ អ្នកធ្វើច្បាប់ជានិច្ចកាល ត្រូវប្រាកដថា នឹងគ្មានការផ្តល់ការលើកលែងនៃច្បាប់ ដែលរំលោភគោលការណ៍សមភាពឡើយ ។ ប្រសិនបើ អ្នកធ្វើច្បាប់ធ្វើការបែងចែងរវាង ក្រុមមនុស្សផ្សេងៗនោះ ការបែងចែកនេះ ត្រូវតែមានហេតុផលត្រឹមត្រូវ ។ ឋានៈសង្គមខ្ពង់ខ្ពស់របស់បុគ្គលទាំងនោះ ឬដើមកំណើត ជាតិសាសន៍ ឬលក្ខណៈបុគ្គលដទៃទៀត ដូចមានចែងនៅក្នុងមាត្រា៣១ II CC មិនមែនជាមូលហេតុដើម្បី សំអាងហេតុចំពោះករណីលើកលែង ឬការប្រព្រឹត្តិពិសេសណាមួយឡើយ ។

ឧទាហរណ៍:

ច្បាប់មួយ ដែលចែងថា ប្រជាពលរដ្ឋទាំងអស់ "លើកលែងតែមន្ត្រីជាន់ខ្ពស់" ត្រូវទទួលទោសចំពោះការបំពានក្រមព្រហ្មទណ្ឌ មិនមានលក្ខណៈទូទៅទេ ហើយថែមទាំងបំពានលើគោលការណ៍សមភាព ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញទៀតផង ។ វាជាករណីអធម្មនុញ្ញភាព ។

## III) ច្បាប់ត្រូវមានលក្ខណៈ "អរូបី":

ច្បាប់ត្រូវផ្តល់ជាវិធានទូទៅមួយ ដែលអាចអនុវត្តចំពោះករណីផ្សេងៗ ដោយបំពេញទៅតាមលក្ខខណ្ឌនៃមាត្រាច្បាប់ ។ ច្បាប់ត្រូវផ្តល់ជាដំណោះស្រាយទូទៅចំពោះបញ្ហា ហើយត្រូវផ្តល់ជាការណែនាំអំពីរបៀបដោះស្រាយទំនាស់រួម ។ ដូច្នេះ ច្បាប់**មិនត្រូវដោះស្រាយតែករណីមួយនោះទេ ប៉ុន្តែត្រូវដោះស្រាយករណីស្រដៀងៗគ្នា ដែលអាចកើតមានឡើងនៅពេលអនាគត** ។ បើមិនដូច្នេះទេ ច្បាប់មិនបានផ្តល់ជាដំណោះស្រាយទំនាស់មួយ ដែលអាចព្យាករបាន និងស្ថិតស្ថេរ និងក្របខ័ណ្ឌវិធានមួយ ដែលជាមគ្គុទេសន៍ និងការណែនាំសំរាប់ប្រជាពលរដ្ឋឡើយ ។

ឧទាហរណ៍:

"ច្បាប់ស្តីពីសាការី" ដែលគ្រាន់តែចែងអំពីឈ្មោះ និងតែងតាំងបុគ្គលម្នាក់ ដូចជាថា "ចាប់ពីពេលនេះទៅលោក អ៊ិច ត្រូវបានតែងតាំងជាអគ្គសាការី"នោះ ពុំមានន័យទូលំទូលាយទេ ។ ច្បាប់នេះ គ្រាន់តែអាចដោះស្រាយបញ្ហាជាក់ស្តែង ដែលបំពេញតំរូវការនៃការចង់បានអគ្គសាការីប៉ុណ្ណោះ ។ ប៉ុន្តែ មិនបានផ្តល់ជាដំណោះស្រាយណាមួយអំពីមធ្យោបាយជ្រើសរើសបុគ្គលនោះនាពេលអនាគត និងអំពីអ្វីដែលត្រូវធ្វើ ប្រសិនបើបុគ្គលដែលត្រូវបានតែងតាំងនោះមិនអាចបំពេញតួនាទី ឬទទួលមរណភាព ឬអវត្តមាននោះឡើយ ។ ជាងនេះទៀត ច្បាប់ត្រូវតែបញ្ចូលបញ្ញត្តិនានា ដែលផ្តល់នូវក្របខ័ណ្ឌទូទៅមួយស្តីអំពីសិទ្ធិ និងករណីយកិច្ច សំរាប់អ្នកចូលកាន់តំណែងនេះនាពេលអនាគតផងដែរ ។

## IV) ច្បាប់ត្រូវមានលក្ខណៈ "ច្បាស់លាស់":

ល័ក្ខខ័ណ្ឌតំរូវដ៏សំខាន់បំផុតសំរាប់ច្បាប់ **គឺការបង្កើតច្បាប់ត្រូវមានលក្ខណៈច្បាស់លាស់បំផុត តាមដែលអាចធ្វើទៅបាន** ។ មានហេតុផលចំបងៗពីរសំរាប់ល័ក្ខខ័ណ្ឌនេះ :

ហេតុផលមួយ គឺថាច្បាប់ត្រូវតែផ្តល់ជា :

- ការណែនាំចំពោះប្រជាពលរដ្ឋ អំពីអ្វីដែលគេត្រូវធ្វើ និងអ្វីដែលគេមិនត្រូវធ្វើ
- ការណែនាំចំពោះផ្នែកនិតិប្រតិបត្តិ អំពីករណីយកិច្ចដែលត្រូវបំពេញ
- គោលការណ៍ណែនាំចំពោះតុលាការ អំពីអ្វីដែលត្រូវហាមឃាត់ និងអ្វីដែលត្រូវបានអនុញ្ញាត ។

នៅពេល រដ្ឋធម្មនុញ្ញកម្ពុជាទាមទារឱ្យប្រជាពលរដ្ឋ (មាត្រា៤៩ I CC) និងរដ្ឋាភិបាល (មាត្រា៥២ ប្រយោគទី២ CC) គោរពច្បាប់ និង ទាមទារឱ្យតុលាការការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋនោះ (មាត្រា១២៨ II CC) **រដ្ឋធម្មនុញ្ញនេះ ត្រូវតែមានលក្ខណៈច្បាស់លាស់សំរាប់ប្រជាពលរដ្ឋទាំងអស់ និងស្ថាប័នទាំងនេះថា តើអ្វីខ្លះដែលស្របច្បាប់ ហើយអ្វីខ្លះដែលខុសច្បាប់ យោងតាមច្បាប់ជាធរមាន** ។ បើមិនដូច្នេះទេ ទាំងប្រជាពលរដ្ឋ ទាំងស្ថាប័នដូចពោលខាងលើនេះ មិនអាចប្រព្រឹត្តិបានត្រឹមត្រូវ និងសមស្របឡើយ ពីព្រោះបទបញ្ញាដែលច្បាប់ចេញមកនោះ គ្មានភាពច្បាស់លាស់គ្រប់គ្រាន់អាចឱ្យគេយល់បាន ។ ជាងនេះទៀត វាគ្មានលក្ខណៈច្បាស់លាស់ថា តើមានការកំណត់ និងការដាក់កំហិតអ្វីខ្លះ ដែលច្បាប់ដាក់ទៅលើសិទ្ធិមនុស្ស ។

ដូច្នេះ ការសំដែងឆន្ទៈប្រជាពលរដ្ឋ មិនច្បាស់លាស់នៅក្នុងអត្ថបទច្បាប់ រឹតតែនាំឱ្យមានទំនាស់ដោះស្រាយមិនចេញ ដែលតាមពិតច្បាប់នោះគួរតែអាចដោះស្រាយបាន ។ ច្បាប់មិនច្បាស់លាស់ អាចនាំឱ្យមានទំនាស់កាន់តែច្រើនឡើង ដោយសារការយល់ច្រឡំ ការបកស្រាយផ្សេងៗគ្នា និងភាពមិនអាចព្យាករបាននៃសិទ្ធិ និងករណីកិច្ច ។

ហេតុផលផ្សេងទៀត ដែលតំរូវឱ្យអត្ថបទច្បាប់មានលក្ខណៈច្បាស់លាស់នោះ គឺថា ការប្រើប្រាស់ពាក្យពេចន៍មិនច្បាស់លាស់នៅក្នុងអត្ថបទច្បាប់ **អាចបើកឱកាសឱ្យផ្នែកនីតិប្រតិបត្តិ ឬតុលាការបកស្រាយអត្ថបទច្បាប់នោះតាមបែបអត្តនោម័តបាន** ។ ដូច្នេះ គោលការណ៍នៃការបែងចែកអំណាច នឹងត្រូវរំលោភពីព្រោះការសំរេចចិត្តគ្មានភាពច្បាស់លាស់របស់អ្នកធ្វើច្បាប់ បណ្តាលឱ្យអំណាចទាំងពីរនេះ ក្នុងករណីមានទំនាស់បំពេញគម្លាត ឬផ្នែកមិនច្បាស់នៃអត្ថបទច្បាប់នោះដោយគំនិតរបស់គេផ្ទាល់ចំពោះដំណោះស្រាយ ។ ទីបំផុតច្បាប់នេះនាំឱ្យមានភាពអយុត្តិធម៌ ដោយសារការគ្រប់គ្រង និង ការអនុវត្តន៍ច្បាប់មិនស្មើភាព ។ ប្រសិនបើគ្មានគោលការណ៍ណែនាំច្បាស់លាស់នៅក្នុងអត្ថបទច្បាប់ទេនោះ មន្ត្រីរដ្ឋបាលម្នាក់អាចនឹងដោះស្រាយករណីមួយតាមរបៀបផ្សេង ហើយមន្ត្រីរដ្ឋបាលម្នាក់ទៀត អាចដោះស្រាយករណីស្រដៀងគ្នានេះ តាមរបៀបផ្សេងមួយទៀតជាពុំខាន ។

<u>ឧទាហរណ៍:</u>

ពង្រាងច្បាប់ស្តីអំពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ (មាត្រា ៣ និង ៤) ចែងថា "មន្ត្រីតុលាការ" ត្រូវបានលើកលែងពីបំរាម ជាទូទៅមិនឱ្យកាន់កាប់អាវុធ ហើយអាចប្រើប្រាស់អាវុធ ។

ច្បាប់នេះ ពុំបានបញ្ជាក់អំពីន័យនៃពាក្យ"មន្ត្រីតុលាការ" ឱ្យបានច្បាស់លាស់ទេ ។ ក្នុងន័យនេះអាចជាចៅក្រម ព្រះរាជអាជ្ញា ឬគ្រាន់តែជាក្រឡាបញ្ជីធម្មតា ឬមន្ត្រីរាជការ ដែលបំរើការនៅក្នុងក្រសួង ។ ប្រសិនបើនិយមន័យនៅតែមានលក្ខណៈមិនច្បាស់លាស់ ដូចដែលមានចែងនៅក្នុងពង្រាងច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ គ្រប់គ្នា នឹងជ្រើសរើសយកការបកស្រាយដោយខ្លួនឯងដែលគេយល់ថាសមស្របបំផុតចំពោះខ្លួនគេ ។ ករណីនេះ វាផ្ទុយនឹងគោលការណ៍ដែលថាច្បាប់ត្រូវតែ អរូបី ទូទៅ និងយុត្តិធម៌ ។

# នីតិរដ្ឋ

| មុខងាររបស់ច្បាប់ | ការការពារសិទ្ធិមនុស្ស | ការបែងចែកអំណាច |
| --- | --- | --- |
| **១) ទាក់ទងទៅនឹងសិទ្ធិមនុស្ស**<br>ច្បាប់:<br>• ដោះស្រាយជំលោះដោយធ្វើការថ្លឹងថ្លែងសិទ្ធិមនុស្ស<br>• កំណត់គោលបំណង និងប្រពល-ភាពនៃការដាក់កំហិតសិទ្ធិ<br><br>**២) ទាក់ទងទៅនឹងគោលការណ៏នៃការបែងចែកអំណាច**<br>ច្បាប់:<br>• ការសំដែងនូវឆន្ទៈរបស់ប្រជាពលរដ្ឋ<br>• កំណត់នូវអំណាចនីតិប្រតិបត្តិ<br>• ធ្វើជាម៉ែត្រសំរាប់ប្រព័ន្ធតុលាការ | **១) ច្បាប់ដោះស្រាយជំលោះរវាងសិទ្ធិនានា**<br>អ្នកច្បាប់ត្រូវតែ:<br>• ទទួលស្គាល់សិទ្ធិ<br>• យកសិទ្ធិទាំងនោះដើម្បីធ្វើការពិចារណា<br>• និងស្រាវជ្រាវរកតុល្យភាពរវាងសិទ្ធិក្នុងជំលោះ (= ដំណោះស្រាយដែលការពារសិទ្ធិទាំង ២ ឱ្យស្មើគ្នា<br><br>**២) ច្បាប់ចែងដាក់កំហិតទៅលើសិទ្ធិ:**<br>លក្ខខណ្ឌក្នុងការដាក់កំហិត:<br>• **តាមទំរង់នៃច្បាប់តែប៉ុណ្ណោះ** (មិនមែនតាមរយៈប្រកាស ឬអនុក្រិត្យនោះទេ)<br>• **មានគោលបំណងការពារសេរីភាពអ្នកដទៃតែប៉ុណ្ណោះ** (ឬគោលបំណងទាំងនោះមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ)<br>• **មានប្រពលភាពសមមាត្រ** (ការដាក់កំហិតលើសិទ្ធិ មិនត្រូវខ្លាំងជាងការចាំបាច់នេះទេ) | **ការសំដែងឆន្ទៈរបស់ប្រជាពលរដ្ឋ**<br><br>**បញ្ហាសំខាន់ត្រូវដោះស្រាយដោយរដ្ឋសភាតាមរយៈច្បាប់** (មិនមែនដោយរដ្ឋាភិបាល តាមរយៈប្រកាស ឬអនុក្រឹត្យឡើយ)<br><br>**គ្មានប្រតិភូកម្មនៃអំណាចធ្វើច្បាប់ទៅ ឱ្យនីតិប្រតិបត្តិ** (គ្មានមាត្រានៃច្បាប់ណាមួយ ដែលទុកការសំរេចសំខាន់ៗ ជូនរដ្ឋាភិបាលឡើយ)<br><br>**ភាពខ្វះចន្លោះនៃច្បាប់ ជាការទុកឱកាសឱ្យ រដ្ឋាភិបាល និងតុលាការ** |

→

| ច្បាប់ទាំងឡាយត្រូវតែ... |
| --- |
| ច្បាប់ត្រូវតែ:<br><br>• **យុត្តិធម៌**<br>ធម្មនុញ្ញភាព និង ការគោរពសិទ្ធិមនុស្ស<br><br>• **ទូទៅ**<br>មិនអនុវត្តចំពោះតែបុគ្គលមួយចំនួនប៉ុណ្ណោះទេ តែអនុវត្តចំពោះប្រជាពលរដ្ឋទាំងអស់<br><br>• **អរូបី**<br>បញ្ញត្តិនូវវិធានមួយសំរាប់ករណីដូចៗគ្នា ដែលអាចកើតមាននៅពេលអនាគត មិនមែនសំរាប់ករណីតែមួយនោះទេ<br><br>• **ច្បាស់លាស់**<br>វាក្យស័ព្ទច្បាស់លាស់ |

## ? សំនួរសិក្សាទី ១៣

ក) តើបុព្វកថានៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្សបាននិយាយអ្វីខ្លះអំពី "នីតិរដ្ឋ" ?

ខ) តើមាត្រា២៩ នៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្ស និយាយអ្វីខ្លះអំពីមុខងាររបស់ច្បាប់? សូមធ្វើការដកស្រង់ ឱ្យបានច្បាស់លាស់ និងផ្ដល់នូវការពណ៌នាសង្ខេបអំពីមុខងាររបស់ច្បាប់!

## ? សំនួរសិក្សាទី ១៤

បណ្ដាបទដ្ឋានគតិយុត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជាដែលអនុម័តដោយរដ្ឋសភាហើយ ត្រូវតែស្របទៅនឹងរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។

សូមធ្វើការដកស្រង់ឱ្យបានច្បាស់លាស់(!) យ៉ាងតិចឱ្យបាន២មាត្រា នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាដែលបង្ហាញថា បទដ្ឋានគតិយុត្តិទាំងនោះត្រូវតែមានធម្មនុញ្ញភាព ។

## ? សំនួរសិក្សាទី ១៥

បណ្ដាបញ្ហាសំខាន់ៗនៅក្នុងសង្គម ត្រូវតែដោះស្រាយ និងបញ្ញត្តិដោយច្បាប់ ។ សូមធ្វើការដកស្រង់ឱ្យបានច្បាស់លាស់ នូវមាត្រាចំនួន ៥ នៃជំពូកពីមាត្រា៣១ ដល់ មាត្រា៥០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងច្បាស់ថាបញ្ហាណាមួយ"ត្រូវកំណត់ដោយច្បាប់" ។

## ? សំនួរសិក្សាទី ១៦

ចូរអានអត្ថបទសង្ខេបខាងក្រោមដែលដកស្រង់ចេញពីសារពតិមាន The Cambodian Daily ចេញផ្សាយថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៣ ។

ការអនុវត្តន៍របស់រដ្ឋាភិបាលគឺមិនមែនការជ្រើសរើសជនពិការមកធ្វើជាគ្រូបង្រៀនទេ ប៉ុន្តែបែរជាបំរាមពួកគេពីការចូលរួមការងារនៅសាលាសាធារណៈ ដែលជាហេតុបង្កឱ្យមានសំរែកពីអង្គការក្រៅរដ្ឋាភិបាល ពីគ្រូបង្រៀន និងសិស្សដែលជាជនពិការ ថាជាការរំលោភបំពានសិទ្ធិមនុស្ស ។

លោក ជ័យ ចាប អនុរដ្ឋលេខាធិការក្រសួងអប់រំ បានមានប្រសាសន៍ថា រដ្ឋាភិបាលបានបញ្ឈប់ការជ្រើសរើសគ្រូបង្រៀនជាជនពិការនៅក្នុងឆ្នាំ ១៩៩៣ ពីព្រោះចាប់ពីពេលនោះមក ប្រទេសកម្ពុជាមានចំនួនគ្រូបង្រៀនដែលមិនមែនជាជនពិការគ្រប់គ្រាន់ ហើយកូនសិស្សចង់បានគ្រូបង្រៀនដែលមានកាយសម្បទាមាំមួនល្អ ។

ផ្ទុយមកវិញ អង្គការក្រៅរដ្ឋាភិបាល គ្រូបង្រៀន និងសិស្សដែលជាជនពិការ បានដកស្រង់បទពិសោធដោយពួកគេផ្ទាល់នៅឯ "ឡាវ៉ាឡា" សាលាឯកជនមួយនៅខេត្តកណ្ដាល ដែលទទួលគ្រូបង្រៀនដែលជនពិការឱ្យធ្វើការ ។ គ្រូបង្រៀនពិការទាំងនោះ ត្រូវបានចាត់ទុកថាមានតួនាទីជាគំរូវិជ្ជមានមួយដល់សិស្សជាជាងគ្រូដែលមានកាយសម្បទាធម្មតា និងអាចលើកទឹកចិត្តដល់សិស្សឱ្យចេះតស៊ូក្នុងជីវិតរបស់ពួកគេ ។

ក) តើបំរាមរបស់រដ្ឋាភិបាលទៅលើគ្រូបង្រៀនពិការ បានដាក់កំហិតលើសិទ្ធិមួយណា? ចូរបញ្ជាក់ពីសិទ្ធិទាំងនោះ និងមាត្រាច្បាប់ជាតិ និងអន្តរជាតិ!

ខ) សូមបើកមើលគេហទំព័រដូចខាងក្រោម :

ចូលទៅ www.online.com.kh/users/kid,

→ បន្ទាប់មក "**Related Link**"

→ រួច "**International Institutions and Law Texts of International Constitutions and Treaties**"

→ បន្ទាប់មកទៀត "**University of Minnesota**"

→ រួចហើយ "**Treaties and other Instruments organized by subject matter**"

→ និងចុងបញ្ចប់ "**Disabled Persons**"

សូមរកសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ដែលគ្របដណ្តប់ករណីគ្រូបង្រៀនដែលរៀបរាប់ខាងលើ និងតើមាត្រានៃសេចក្តីថ្លែងការណ៍ណាមួយដែលជាប់ពាក់ព័ន្ធ - សូមធ្វើការដកស្រង់តែមាត្រាតែមួយបានហើយ!

## ? សំនួរសិក្សាទី ១៧

រាជរដ្ឋាភិបាលចង់ធ្វើការប្រមូលលុយពីអ្នកបើកបររថយន្តទាំងឡាយ ដែលប្រើប្រាស់ផ្លូវជាតិ ។ តើករណីនេះចាំបាច់ដែរឬទេ ដែលថា ការប្រមូលលុយថ្លៃផ្លូវបែបនេះ ត្រូវកំណត់ដោយច្បាប់ដែលអនុម័តដោយរដ្ឋសភា? ឬក៏រាជរដ្ឋាភិបាលអាចសំរេចបញ្ហានេះដោយមិនចាំបាច់មានច្បាប់ ?

សូមផ្តល់នូវមូលហេតុតាមផ្លូវច្បាប់សំរាប់ចំលើយនេះ!

## ? សំនួរសិក្សាទី ១៨

សូមធ្វើការស្រមៃថា អ្នកច្បាប់បានពង្រាងច្បាប់ថ្មីមួយ "ច្បាប់ស្តីពីចរាចរ នៃរថយន្តតាមផ្លូវសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា" ។

តើវាចម្ងន្ទុញ្ញភាពដែរឬទេ ប្រសិនបើអ្នកច្បាប់ទាំងនោះបានអនុម័តមាត្រាមួយនៃច្បាប់នោះ ដែលមានអត្ថន័យដូចខាងក្រោម :

> "រថយន្តទាំងឡាយ ត្រូវតែមានលេខអាជ្ញាប័ណ្ណ ។ ព័ត៌មានលំអិតស្តីពីទំហំ ពណ៌ និង លំដាប់លេខអាជ្ញាប័ណ្ណ ត្រូវកំណត់ដោយអនុក្រឹត្យក្រសួងសាធារណការ និងដឹកជញ្ជូន?"

សូមផ្តល់នូវមូលហេតុតាមផ្លូវច្បាប់សំរាប់ចំលើយរបស់អ្នក!

## ? សំនួរសិក្សាទី ១៩

ពុទ្ធសាសនិកកម្ពុជាភាគច្រើនមានអារម្មណ៍ថាត្រូវបានរំខានដោយ បេសកជនគ្រីស្ទបរិស័ទបរទេស ដែលមកផ្ទះពួកគាត់ ហើយគោះទ្វារ និងព្យាយាមបញ្ចុះបញ្ចូលពួកគាត់ឱ្យក្លាយជាគ្រីស្ទបរិស័ទ ។

សូមធ្វើការស្រមៃថា អ្នកច្បាប់បានអនុម័តនូវ "ច្បាប់ ស្តីពីសកម្មភាពរបស់បេសកជន" ដែលរួមមានមាត្រាមួយដែលមាន អត្ថន័យដូចខាងក្រោម:

> "ផ្នែកទី ១: ច្បាប់នេះ មានគោលដៅក្នុងការការពារសន្តិភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា ។
> ផ្នែកទី ២: រាល់សកម្មភាពបេសកជនបរទេសកាន់សាសនាគ្រីស្ទទាំងឡាយនៅក្នុងប្រទេសកម្ពុជា (ដោយមិនកំណត់ថាសកម្មភាពនោះអនុវត្តននៅពេលណា ដោយមធ្យោបាយអ្វីនោះទេ) ត្រូវហាមឃាត់ជាដាច់ខាត ចាប់ពីថ្ងៃនេះតទៅ ។"

តើមាត្រានៃច្បាប់ដែលបានពោលខាងលើនេះ មានធម្មនុញ្ញភាពដែរឬទេ ? សូមផ្តល់នូវមូលហេតុតាមផ្លូវច្បាប់សំរាប់ចំលើយរបស់អ្នក!